Diploma Programme
Programme du diplôme
Programa del Diploma

# Khmer A: literature – Standard level – Paper 1
# Khmer A : littérature – Niveau moyen – Épreuve 1
# Khmer A: literatura – Nivel medio – Prueba 1

Wednesday 4 May 2016 (afternoon)
Mercredi 4 mai 2016 (après-midi)
Miércoles 4 de mayo de 2016 (tarde)

1 hour 30 minutes / 1 heure 30 minutes / 1 hora 30 minutos

---

### Instructions to candidates

- Do not open this examination paper until instructed to do so.
- Write a guided literary analysis on one passage only. In your answer you must address both of the guiding questions provided.
- The maximum mark for this examination paper is **[20 marks]**.

### Instructions destinées aux candidats

- N’ouvrez pas cette épreuve avant d’y être autorisé(e).
- Rédigez une analyse littéraire dirigée d’un seul des passages. Les deux questions d’orientation fournies doivent être traitées dans votre réponse.
- Le nombre maximum de points pour cette épreuve d’examen est de **[20 points]**.

### Instrucciones para los alumnos

- No abra esta prueba hasta que se lo autoricen.
- Escriba un análisis literario guiado sobre un solo pasaje. Debe abordar las dos preguntas de orientación en su respuesta.
- La puntuación máxima para esta prueba de examen es **[20 puntos]**.

2216 – 0567



© International Baccalaureate Organization 2016

International Baccalaureate®
Baccalauréat International
Bachillerato Internacional

សូមអ្នកធ្វើការវិភាគបែបអក្សរសិល្ប៍ទៅលើអត្ថបទ**មួយ**គត់។ ក្នុងចម្លើយរបស់អ្នក អ្នកត្រូវឆ្លើយតបនឹងសំណួរទាំងពីរដែលបានចោទសួរ។

**1.**

ស្រស់ស្រី ងើបមុខឡើងមើលទៅអ្នកសួរប្រទាក់នឹងភ្នែកអ្នកកំលោះសម្លឹងមើលមកនាងដែរ ! កែវភ្នែក របស់គេស្រទន់ណាស់មានលក្ខណៈសុភាពរាបសាបំផុត នាងក្រមុំអៀនភ្លេចរឿងភ័យអម្បាញ់មិញ ផាណូដាក់កង់ចតលើចិញ្ចើមថ្នល់រត់មកមើលនាងដែរ !

- ស៊ីរ៉ា យ៉ាងម៉េចទៅហើយហ្នឹង ? មានរបួសត្រង់ណាទេ ?

- អត់ទេ... អត់អីទេផាណូ !

- ស៊ីរ៉ាប្រុងទៅណាហ្នឹង ខ្ញុំជូនទៅ !

មាណវីមិនតបនឹងផាណូទេ នាងលួចមើលម្ចាស់ឡានបន្តិច ហើយដើរឆ្លងទៅម្ខាងតាមផាណូ ! ម្ចាស់ឡានសង្ហាតាមមើលនាងទាំងស្តាយ រួចបើកឡានចេញទៅ ។ ផាណូជូនស៊ីរ៉ាមកដល់ផ្ទះដែលគេចេះតែគិតថាក្រុមគ្រួសារនេះរីករាយណាស់ពីពេលមុន ចុះពេលនេះប្រែជាក្រៀមស្រពោនទៅវិញ ។ ឪពុកស៊ីរ៉ាគេងជាប់នឹង កន្ទេលម្តាយនាងនៅថែជំងឺជាប្រចាំ ធ្វើឲ្យគ្រួសារនេះកាន់តែពិបាកឡើងដោយគ្មានអ្នកណាចេញទៅរកស៊ី ។

ផាណូដកដង្ហើមធំ:

- ស៊ីរ៉ាគិតឈប់រៀនពិតមែនឬ ?

មាណវីងើបមុខក្រៀមក្រំសម្លឹងមើលទៅម្តាយ រួចឆ្លើយទៅផាណូ:

- ចាស ពិតមែនហើយផាណូ !

- ទ្រាំបន្តិចទៀតសិនទៅស៊ីរ៉ា ខ្ញុំនឹងជួយរំលែកមិត្តខ្លះបើមិត្តតស៊ូរៀនទៅមុខទៀត ! ព្រោះស៊ីរ៉ាជាសិស្សពូកែនៅក្នុងសាលាផងដឹងដែរទេ ?

- អរគុណហើយផាណូ ខ្ញុំនៅមានឪពុកម្តាយពិបាកបន្តិចគ្រាន់បានគ្នាជួយគិត ចុះផាណូឯងវិញមានតែម្នាក់ឯងកម្សត់ជាងខ្ញុំទៅទៀត ។

ផាណូធ្លាក់ទឹកមុខនឹងពាក្យបដិសេធរបស់ស្រីល្អ !

- កូនកំព្រាម្នាក់មិនអាចធ្វើល្អចំពោះស៊ីរ៉ាឯងបានទេឬ ?

-កុំយល់ដូច្នេះអីផាណូ... ខ្ញុំស្រឡាញ់អំពើល្អរបស់ផាណូណាស់ ប៉ុន្តែខ្ញុំមិនចង់ឲ្យមិត្តពិបាកដោយសារតែរូបខ្ញុំ !

អ្នកកំលោះខាំមាត់តប:

- ខ្ញុំនឹងសម្រេចចិត្តជួយស៊ីរ៉ាខ្លះទៅតាមសមត្ថភាពរបស់ខ្ញុំ អឺខ្ញុំសូមលាសិនហើយ !

ផាណូលាឪពុកម្តាយស៊ីរ៉ាត្រឡប់ទៅវិញដោយកិរិយាសុភាពបំផុត ឪពុកម្តាយរបស់ស្រស់ស្រីមើលដំណើរអ្នកកំលោះដោយក្រៀមក្រំទាំងប្រឹងញញឹម !

- គេជាមិត្តរបស់កូនឬស៊ីរ៉ា ?

- ចាស គេរៀនជាមួយនឹងកូន ។

- ល្អណាស់ មានចរិតគួរឲ្យស្រឡាញ់មែន !

ស៊ីវ៉ាញញឹមតាមឪពុកដែរ ព្រោះឃើញឪពុកនាងមានទឹកមុខរាងស្រស់ជាងថ្ងៃមុន ។ ម្ដាយស៊ីវ៉ាបន្តប្រយោគពីប្ដី:

- ស៊ីវ៉ា កូនមិនត្រូវមានគំនិតឈប់រៀននោះទេ បើស្រឡាញ់ឪពុកម្ដាយ កូនត្រូវខិតខំរៀនព្រោះឆ្នាំនេះជា ឆ្នាំប្រឡងផង ម្ដាយចង់ឃើញកូនស្រីមានតម្រិះនឹងគេ ! អន់ណាស់ក៏មានសញ្ញាបត្រ១សន្លឹកដែរណ៎ាកូន !

- ត្រូវហើយ ប៉ាក៏គិតយ៉ាងនេះដែរណ៎ាកូន ! កុំថ្ងៃក្រោយ កូនពិបាកដូចជាប៉ា រកស៊ីនឹងកម្លាំងពិបាកណាស់កាលណាឈឺអត់លុយហើយ !

ស៊ីវ៉ាមិនស្ដី តែនាងស្ដាប់ឪពុកម្ដាយណាស់ សៀវភៅដែលនាងសម្រេចចិត្តថាលែងកាន់ នឹងត្រូវផ្លាស់ចិត្តមកចាប់កាន់ឡើងវិញ ទើបប្ដេជ្ញាប្រឡងយកសញ្ញាបត្របឋមភូមិឲ្យបានដើម្បីបំពេញចិត្តអ្នកមានគុណ ។ ផាណូស្រឡាញ់ស៊ីវ៉ាណាស់ តែគេជាកូនកំព្រាមានអំណត់តស៊ូក្នុងឆាកជីវិតរស់នៅ មិនដែលបញ្ចេញពាក្យសម្ដី អ្វីធ្វើឲ្យលើសពីក្របខណ្ឌមិត្តភាពឡើយ ។ គេតែងតែជួយឧបត្ថម្ភស៊ីវ៉ាខ្លះៗ ដោយឆ្លៀតពេលយប់ទៅរត់តុនៅហាងមួយមិនឆ្ងាយប៉ុន្មានពីកន្លែងគេស្នាក់នៅនោះឡើយ ។

ទឹម ម៉ានី ( ស្មេរ ), *ខ្សែជីវិត*

(a) ចូរអ្នកធ្វើការវិភាគទៅលើវិធីសាស្រ្តបង្ហាញតួអង្គនៅក្នុងអត្ថបទដកស្រង់ខាងលើ? តើវិធីសាស្រ្តបង្ហាញតួអង្គនេះរួមចំណែកដល់ការយល់ដឹងរបស់អ្នកអំពីអត្ថបទដូចម្ដេចខ្លះ?

(b) តើអ្នកនិពន្ធប្រើបច្ចេកទេសសរសេរបែបណាខ្លះដើម្បីបង្ហាញគំនិតសំខាន់របស់រឿងនេះ?

**2.**

## ការសន្សំបុណ្យកុសល

ជាធម្មតា ដាំដុះពូជណា ផ្លែផ្កាពូជនោះ
ពូជត្រង់ជួបត្រង់ ពូជស្មោះជួបស្មោះ បានផលទាំងអស់
ផលពូជបានដាំ ។

បើដាំពូជបុណ្យ ពូជនោះជាគុណ តែងនៅរង់ចាំ
មិនរត់ចោលម្ចាស់ ទៀងណាស់ចំណាំ ទោះរយពាន់ឆ្នាំ
ក៏ចាំឱ្យផល ។

ពេលបានឱកាស ពូជបុណ្យនេះច្បាស់ ប្តូរផ្លាស់កង្វល់
ជួយដល់ម្ចាស់ភ្លាម ពុំមានសំណល់ ជួយដោះអំពល់
គ្រប់ពេលវេលា ។

រីឯពូជបាប ជាពូជថោកទាប ពូជខ្លីជន្មា
ពូជក្រលំបាក ពូជវេទនា វិកលពិការ
ក៏ឱ្យផលដែរ ។

ពូជបាបនិងបុណ្យ បើមួយណាធ្ងន់ ជាងគឺត្រូវតែ
ឱ្យផលបានមុន មិនចេះប្រួលប្រែ មិនចេះបង្វែរ
បញ្ច្រាសទិសឡើយ ។

ដូច្នេះគ្រប់គ្នា សូមគិតពិចារណ៍ កុំនៅកន្តើយ
បុណ្យត្រូវសន្សំ ឱ្យមាំអ្នកអើយ ព្រោះបុណ្យនេះហើយ
ជួយអ្នកឱ្យសុខ ។

អ្នកចាំឱ្យច្បាស់ បុណ្យស្រួលធ្វើណាស់ អ្នកកុំស្មាញស្មុគ្រ
ធ្វើបានគ្រប់គ្រា មហាស្រណុក បើគេមានទុក្ខ
ជួយខ្លះកុំខាន ។

បើចង់បានបុណ្យ បញ្ញាឱ្យធ្ងន់ ណាជនគ្រប់ប្រាណ
ត្រឡប់ផ្លាស់ប្រែ ខ្មៅឱ្យសបាន នេះហើយលំអាន
អ្នកសន្សំបុណ្យ ។

បើមើលគេខុស កុំស្តីបន្ទុះ វាចាធ្ងន់ៗ
និយាយឱ្យល្អ ប្រាប់ពីទោសទណ្ឌ ប្រាប់ផ្លូវកែគន់
អាក្រក់ទៅល្អ។

បើគេធ្វើត្រូវ សរសើរខ្លះទៅ ឬជួយអបអរ
ត្រូវឱ្យឱកាស គេធ្វើបន្ត ចិត្តត្រូវស្មោះស
កុំគិតរំខាន ។

ចេង តារា, *សួនកំណាព្យថ្មី* (2008)

(a) ចូរធ្វើការពិនិត្យមើលថាតើអ្នកនិពន្ធបង្ហាញគំនិតចំបងរបស់កំណាព្យដកស្រង់ខាងលើយ៉ាងដូចម្តេចខ្លះ ហើយថាតើការបង្ហាញនេះមានឥទ្ធិពលដល់ការយល់ដឹងរបស់អ្នកទៅលើកំណាព្យយ៉ាងដូចម្តេចខ្លះ?

(b) ចូរធ្វើការវិភាគទៅលើរចនាសម្ព័ន្ធរបស់អត្ថបទកំណាព្យដកស្រង់ខាងលើនេះ?